# អត្ថបទរឿង "ម្សិលមិញ ថ្ងៃនេះ ថ្ងៃស្អែក"

និពន្ធដោយ គឹម ឌីណា

- បងៗស្រទ្បាញ់ សូមទម្លាក់លេខ ទម្លាក់ទីតាំង! ឈុតឡេនេះ លាបហើយជានា សចេញពីខាងក្នុង ត្រឹមរយៈពេល ៣ ថ្ងៃ!

នេះជាសំឡេងរបស់អ្នកលក់ឡេអនទ្បាញ ដែលកំពុងបង្ហូកប្រកាសតាមហ្វេសប៊ុកផេករបស់ខ្លួន។ ខ្ញុំក៏ទម្លាក់លេខ និងទម្លាក់ទីតាំង រួចក៏អូសហ្វេសប៊ុកទៅមើលហាងខោអាវវិញម្ដង។ ខោអាវម៉ូតស្អាតៗជាច្រើន កំពុងទាក់ភ្នែកខ្ញុំសម្បើមណាស់។ ខ្ញុំក៏សម្រេចចិត្តទិញ ពីព្រោះថ្ងៃអាទិត្យនេះ ខ្ញុំត្រូវទៅដើរលេងជាមួយនឹងមិត្តភក្តិរបស់ខ្ញុំផង។

អូ! ខ្ញុំភ្លេចណែនាំខ្លួន! ខ្ញុំឈ្មោះ មាលា អាយុ ២៨ ឆ្នាំ ជាអ្នកគ្រប់គ្រងផ្នែកសេវាអតិថិជន នៅក្រុមហ៊ុនឯកជនមួយ។ គ្រួសាររបស់ខ្ញុំមានសមាជិក ៤ នាក់។ ម៉ាក់ប៉ាខ្ញុំ ខ្ញុំ និងបងប្រុសខ្ញុំ។ ខ្ញុំនិងបងប្រុសខ្ញុំ មិនសូវបានជួបជុំបាយទឹកជាមួយម៉ាក់ប៉ានោះទេ ដោយសារតែយើងរវល់ការងារ ហើយជាពិសេសពេលល្ងាចៗ យើងភាគច្រើនទៅញ៉ាំអីជាមួយនឹងមិត្តភក្តិ ឬក៏អ្នករួមការងារជាមួយ។ ដូច្នេះម៉ាក់និងប៉ា បើទោះមានកូន ក៏ដូចជាគ្មានកូនដែរ ពីព្រោះពួកខ្ញុំមិនសូវបាននៅក្បែរ និងចំណាយពេលជាមួយនឹងពួកគាត់។ បើនិយាយពីថ្ងៃចុងសប្ដាហ៍វិញ កែប កំពត គិរីរម្យ ឬហាងអាហារដែលទើបបើកថ្មីឯណោះទេ ដែលប្រៀបដូចជាផ្ទះទី ២ របស់ខ្ញុំ ពីព្រោះធ្វើការពីចន្ទដល់សុក្រ ខ្ញុំហត់ទាំងកាយ និងចិត្ត ដូច្នេះរាល់ពេលចុងសប្ដាហ៍ ខ្ញុំត្រូវចេះរកសុខដាក់ខ្លួនតាមរយៈការដើរលេង ញ៉ាំអាហារឆ្ងាញ់ ឬប្លែកៗ ដើម្បីជាការផ្ដល់កាដូ ដល់ខ្លួនឯងផង និងមានកម្លាំងចិត្តធ្វើការងារផង។

នៅខ្ទសលំហែ នាឆ្នេរសមុទ្រកែប ខ្ញុំនិងមិត្តភក្តិមួយក្រុម កំពុងតែថតរូបលេងយ៉ាងសប្បាយរីករាយ។ មេឃស្រឡះល្អ ហើយត្រូវនឹងខ្ញុំផាត់មុខផាត់មាត់ស្អាត ស្លៀកពាក់ខោអាវថ្មីៗផង នោះធ្វើឱ្យសម្រស់របស់ខ្ញុំឡើងត្រដែតតែម្ដង។ ក្រោយពីថតរូបរួច ពួកយើងក៏ទៅខ្ទសលំហែវិញ។ អង្គុយបានមួយសន្ទុះ អ្នកលក់ក៏លើកយកបាយម្ហូបមក ដែលមានដូចជាស្ងោរបង្គា ឆាក្ដាមម្រេចខ្ចី គុងយ៉ាំបង្គា មឹកអាំង។ គ្រាន់តែឃើញម្ហូបភ្លាម ពួកខ្ញុំក៏

ប្រញាប់ដួសបាយ ខណៈអ្នកខ្លះក៏លូកដៃទៅចាប់មឹក ចាប់ក្តាម ហើយដាក់ចូលមាត់ញ៉ាំយ៉ាងឆ្ងាញ់។ ខ្ញុំនិងមិត្តភក្តិរបស់ខ្ញុំឈ្មោះសោភា ក៏ចាក់ទឹកត្រីកោះកុងចូលទៅក្នុងកូនចានមួយ ដើម្បីជ្រលក់បង្គាជាមួយគ្នា ពីព្រោះថាអ្នកលក់យកចានមកខ្វះ ហើយណាមួយយើងខ្ជិលហៅគេឱ្យយកមកថែមផង។ យើងទទួលទានអាហារថ្ងៃត្រង់ជាមួយគ្នាយ៉ាងរីករាយ និងស្និទ្ធស្នាលជាទីបំផុត។ ក្រោយទទួលទានហើយ មានអ្នកលក់ទុរេនជិះម៉ូតូហើយស្រែកពពាយនាយ។ យើងក៏ហៅអ្នកលក់មក ដើម្បីទិញទុរេនញ៉ាំ។ ទុរេនកំពតឆ្ងាញ់មែន! សុខា ដែលជាមិត្តភក្តិប្រុសតាំងពីរៀនមហាវិទ្យាល័យជាមួយខ្ញុំ វាញ៉ាំទុរេនមិនអស់ ហើយសល់ទ្បើងពាក់កណ្តាល ស្រាប់តែណារិនឃើញស្តាយពេកក៏និយាយៈ

- សុខាឯងឈប់ហើយ!
- អឺឈប់ហើយ! ដាក់ច្រើនជ្រុល ទ្បើងចង់ចេញមកវិញ!
- អ៊ីចឹងចេះយកអាក្លែបធំទៀតណ៎ា!
- ឯងស្តាយមែន? បើស្តាយយកញ៉ាំទៅ!
- ស្តាយមែនតើ ឯងដូចមិនទាន់ឆ្អែតផង!

តបបណ្តើរ ណារិនក៏យកទុរេន ដែលសុខាញ៉ាំនៅសល់ពាក់កណ្តាលយកមកញ៉ាំបង្ហើយ យ៉ាងស្និទ្ធ ពីព្រោះតាំងពីរៀនជាមួយគ្នាមកពួកយើងទាំង ៤ នាក់ជាមិត្តល្អ ហើយបានអីញ៉ាំ ក៏ចែករំលែកគ្នា ហើយយើងមិនខ្ពើមគ្នាទេ។ ខ្ពើមអី បើពួកយើងអត់មានជំងឺថ្លើមផង! ខ្លាចអីនឹងឆ្លង! ហិហិ ការដើរលេងរបស់យើងបញ្ចប់ទៅដោយភាពសប្បាយរីករាយ និងជាអនុស្សាវរីយ៍មួយដែលមិនអាចបំភ្លេចផង។ យើងក៏មានគម្រោងទៅដើរលេងបរទេសនៅឆ្នាំក្រោយជាមួយគ្នាទៀតផង។ គ្រាន់តែគិត ក៏រំភើបទៅហើយ! ដើរលេងស្រុកគេ ញ៉ាំរបស់ឆ្ងាញ់ៗ ទិញអីវ៉ាន់ប្រេនៗ! ១ ជាតិមានប៉ុន្មានដង! ធ្វើការហត់សឹងស្លាប់ ចុះទៅខ្លាចនិងកំណាញ់អី ត្រឹមរឿងផ្តល់ក្តីសុខឱ្យខ្លួនឯងនោះ! មានជីវិត ត្រូវរស់ឱ្យមានន័យ!

ខ្ញុំមកដល់ផ្ទះនៅម៉ោងប្រហែលជា ១០ យប់! គ្រាន់តែដល់ផ្ទះភ្លាម ខ្ញុំប្រញាប់ទៅយកដបទឹកពីក្នុងទូទឹកកកយកមកញ៉ាំក្អឹក ព្រោះស្រេកពេក ដោយសារមកតាមផ្លូវមិន

ហ៊ានញ៉ាំទឹកច្រើន ព្រោះខ្ជិលចុះបន្ទប់ទឹក។ ញ៉ាំទឹកសល់កន្លះដប ខ្ញុំក៏រកដាក់ទឹកនៅក្នុងទូទឹកកកវិញ ស្រាប់តែបងប្រុសរបស់ខ្ញុំឈ្មោះ ចិត្រា ចេញពីបន្ទប់ទឹក ហើយនិយាយមកកាន់ខ្ញុំ

- កុំទាន់អាលដាក់ បងផឹកសិន!

ខ្ញុំហុចទឹកទៅបងចិត្រា៖

- ថ្ងៃនេះមកផ្ទះលឿនហ្ន៎!

បងចិត្រាផឹកទឹកដែលខ្ញុំរួច ទើបតប។

- ថ្ងៃនេះរាងឈឺក្រពះ នៅផឹកជាមួយពួកម៉ាកអត់បានយូរ!
- អ៊ីចឹងតើបានដល់ផ្ទះលឿន!
- ចុះឯងដើរលេងយូរម៉េស?
- ពេលយប់ជិះយឺតៗ ខ្លាចគ្រោះថ្នាក់!
- ចេះប្រយ័ត្នអ៊ីចឹងល្អហើយ! បងទៅដេកសិនហើយ!
- ចុះម៉ាក់ប៉ាសម្រាន្តអស់ហើយ?
- ពួកគាត់ចូលបន្ទប់តាំងពីម៉ោង ៨ កន្លះម្ល៉េះ!

ឆ្លើយតបនឹងខ្ញុំរួច បងចិត្រាក៏ឡើងទៅបន្ទប់របស់គាត់វិញ ឯខ្ញុំក៏ចូលទៅបន្ទប់របស់ខ្ញុំវិញដែរ។ គ្រាន់តែដល់បន្ទប់ភ្លាម ខ្ញុំប្រញាប់ទម្លាក់ខ្លួនលើពូកភ្លែត មិនទាន់ខ្ជីមុជទឹកទេ ព្រោះហត់ឡើងម៉្លេហើយ! ខ្ញុំស្រវ៉ាយកទូរសព្ទពីក្នុងកាបូប ដើម្បីចុចរូបភាពដែលថតពីថ្ងៃយកមកមើល ហើយក៏បង្ហោះនៅលើហ្វេសប៊ុក ទៅតាមទម្លាប់។

ថ្ងៃនេះ ក្រោយចប់ការប្រជុំនៅកន្លែងធ្វើការ ខ្ញុំនិងអ្នករួមការងារក៏ទៅញ៉ាំបាយហាងដែលនៅក្បែរនោះ។ មួយតុអង្គុយគ្នាប្រហែលជា ៥ នាក់ រៀងចង្អៀតបន្តិច តែយើងចូលចិត្តញ៉ាំជុំគ្នាបែបនេះ ពីព្រោះបានជជែកគ្នាផង និងបានញ៉ាំម្ហូបរបស់គ្នាទៅវិញទៅមកផង។ ៥ នាក់ ៥មុខឯណោះ! ដូចប៊ូហ្វេទៅហើយ! ហិហិ ទោះជាជជែកគ្នាមែន តែពួកខ្ញុំកាន់ទូរសព្ទនៅនឹងដៃរៀងខ្លួន ហើយពេលនោះខ្ញុំស្រាប់តែលាន់មាត់ដោយភ្ញាក់ផ្អើល

ពេលឃើញព័ត៌មានមួយដែលនិយាយពីការផ្ទុះជំងឺកូវីដនៅទីក្រុងវូហាន ប្រទេសចិន។ ដាលីនអ្នករួមការងារជាមួយខ្ញុំនិយាយៈ

- កុំទៅបារម្ភច្រើនពេក នៅឆ្ងាយពីយើងណាស់ វាមិនអីទេ!
- មែនហើយ! គិតច្រើនពេក បារម្ភច្រើនពេក ទៅជាស្រ្តេសហើយឈឺទៅវិញទេ!

សុភីបានតបទៅដាលីន។ ខ្ញុំក៏ងក់ក្បាលយល់ស្រប ហើយក៏ចុចអូសព័ត៌មាននោះ រួចទុកទូរសព្ទនៅលើតុ ហើយនិយាយទៅពួកគេៈ

- នែ៎! និយាយអ៊ីចឹងស្អែកនេះទៅមើលកុនអត់! ចេញរឿងថ្មីទៀតហើយណា៎!
- ឯងថាទៅទិញខោអាវ ចុះឡើង ៥០%ណា៎! (សុភី)
- ឥឡូវអ៊ីចេះ មើលកុនហើយ ចាំទៅទិញខោអាវ! (ដាលីន)
- អូខេ! (មិត្តពីរនាក់ទៀតឆ្លើយព្រមគ្នា)

ព្រឹកឡើង ខ្ញុំក្រោកម៉ោងប្រហែលជា ១០ ព្រឹក ពីព្រោះជាថ្ងៃសៅរ៍។ ខ្ញុំមុជទឹក រៀបចំខ្លួនរួចរាល់ ក៏ចុះមកក្រោម ឃើញម៉ាក់កំពុងតែធ្វើម្ហូប។ ម៉ាក់ប្រញាប់សួរខ្ញុំៈ

- យី! កូនទៅណាហ្នឹង អត់ញ៉ាំបាយសិនទេ ម៉ាក់ខំធ្វើម្ហូបឡើងច្រើន!
- ទៅដើរលេងជាមួយមិត្តភក្តិ អត់បានបាយផ្ទះទេម៉ាក់!
- កូននេះបាយក្រៅរហូត ក្នុងខ្លួនអត់មានជីវជាតិអីទេ!
- ម៉ាក់ថាតែកូន ចុះបងចិត្រានោះ!
- ពីរនាក់ឯង មួយដំបនិងប្អូន!

ខ្ញុំសើច ហើយដើរទៅក្បែរម៉ាក់ រួចឱបគាត់។

- ចាំស្អែក ចាំបាយផ្ទះជុំគ្នាម៉ាក់!

ថាចប់ ខ្ញុំក៏ប្រញាប់ចេញទៅ ព្រោះខ្លាចម៉ាក់ទេសនា។

ខ្ញុំបន្តជីវភាពនៃជីវិតរបស់ខ្ញុំបានយ៉ាងរីករាយ រហូតដល់មានការផ្ទុះជំងឺកូវីដ-១៩ នៅភ្នំពេញ ហើយអ្វីៗក៏បានផ្លាស់ប្តូរ។ ខ្ញុំត្រូវឆ្លាស់ពេលទៅធ្វើការនៅក្រុមហ៊ុន ពោលគឺធ្វើការនៅផ្ទះ ២ ថ្ងៃ ហើយទៅក្រុមហ៊ុន ៣ ថ្ងៃ ពីព្រោះគេកាត់បន្ថយចំនួនមនុស្សទៅធ្វើការ ដើម្បីទប់ស្កាត់ហានិភ័យនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ខ្ញុំត្រូវពាក់ម៉ាស លាង

ដៃឱ្យបានញឹកញាប់ ហើយរក្សាគម្លាត។ ពេលបាយ ខ្ញុំទៅតែពីរនាក់ដាលីន ដោយសារតែមិត្តបីនាក់ទៀត ត្រូវធ្វើការពីផ្ទះ។ ពេលបាយជាមួយដាលីនហ្នឹង ក៏ពួកខ្ញុំដាក់ស្លាបព្រាកណ្ដាល ហើយយើងត្រូវបាញ់តុ បាញ់កៅអី និងបាញ់ដៃជាមួយទឹកអាល់កុលសិន ដើម្បីធានាសុវត្ថិភាព។ ពីណាពីណីមក យើងមិនធ្លាប់ប្រយ័ត្នអ៊ីចឹងពេកនោះទេ តែធ្វើម៉េច បើយើងមិនសម្រប មិនប្រយ័ត្ន អ៊ីចឹងមានតែប្រឈមនឹងការឆ្លង។

នៅពេលល្ងាច ក្រោយចប់ការងារ ខ្ញុំត្រូវទៅផ្ទះ ពោលគឺមិនបានជិះដើរលេង ចូលញ៉ាំអីជាមួយមិត្តវិទ្យាល័យ ឬមិត្តរួមការងារដូចមុនទេ។ ពោលគេក៏ខ្លាចឆ្លង ខ្ញុំក៏ខ្លាចឆ្លង។ ពេលខ្លះយើងខ្ចប់អីយកទៅញ៉ាំនៅផ្ទះ ឬកុម្ម៉ង់តាមអេបឱ្យគេដឹកមកផ្ទះ។ ខ្ញុំបាយផ្ទះជាមួយម៉ាក់ប៉ាបានច្រើនជាងមុន។ ខ្ញុំសង្កេតឃើញថាម៉ាក់ប៉ាខ្ញុំចាស់ច្រើនហើយតើ! ពីមុនម៉េចខ្ញុំមិនដឹង ឬក៏ខ្ញុំមិនដែលមានពេលក្បែរពួកគាត់? ម៉ាក់ប៉ាមើលទៅសប្បាយចិត្តដែលខ្ញុំនៅបាយផ្ទះជាមួយពួកគាត់ តែគាត់នៅតែរអ៊ូរឿងបងចិត្រា។ ម៉ាក់លើកឡើង៖

- បងចិត្រាកូនឯង នៅផឹកដល់យប់ៗ ម៉ាក់ខ្លាចតែថ្ងៃណាមួយនាំកូវីដចូលផ្ទះទេ!
- មែនហើយ ប៉ាម៉ាក់សុទ្ធតែចាស់ៗ ហើយមានជំងឺប្រចាំកាយទៀត! បើឆ្លងមែនសង្ឃឹមតិចណាស់!

ខ្ញុំឮបែបនេះ ក៏អាណិតម៉ាក់ប៉ា ដែលត្រូវបារម្ភនឹងសុខភាពរបស់ខ្លួនរាល់ថ្ងៃ ដោយសារតែបងចិត្រានៅតែមិនចោលទម្លាប់ដើរលេងផឹកស៊ីដល់យប់ៗសោះ! ខ្ញុំក៏ខំលួងម៉ាក់ប៉ា៖

- មិនអីទេម៉ាក់ប៉ា! សំខាន់ម៉ាក់ប៉ាថែសុខភាព ញ៉ាំអាហារសម្បូរជីវជាតិ និងថែទាំសុខភាពផ្លូវចិត្ត! រឿងបងចិត្រា ចាំកូនសាកនិយាយជាមួយពួកគាត់!
- កូននេះជិតការហើយ នៅមិនកែចរិតដើរលេងផឹកស៊ីដាច់យប់ហ្នឹងសោះ!

ម៉ាក់និយាយទាំងតឹងចិត្ត។ ខ្ញុំឯណេះក៏តឹងចិត្តទៅតាមគាត់ដែរ ពីព្រោះសកម្មភាពរបស់បងចិត្រា ធ្វើឱ្យខ្ញុំបារម្ភថាបើគាត់ឆ្លងកូវីដ គាត់ក៏ប្រឈម ពីព្រោះគាត់ផឹកស្រាច្រើនតាំងពីដើម ហើយជាពិសេសគឺអ្នកផ្ទះខ្ញុំទាំងមូលគ្មានអ្នកណាមានសុវត្ថិភាពទេ បើបងចិត្រាអត់គិតគ្រួសារសោះអ៊ីចឹង។ តុផឹកស៊ីជួបជុំ វាសប្បាយមែនហើយ តែបើមានអី

ថ្លោះធ្លោយ ប្រឈមជាងគេគឺម៉ាក់ប៉ាខ្ញុំតែម្តង! កូវីដ-១៩ វាមានរើសអើងមនុស្សពីពេលណា! វារកផ្លូវមករកយើងមិនឃើញទេ បើយើងមិនទៅរកវានោះ!

ចូលមកដល់ក្នុងបន្ទប់ ខ្ញុំក៏ដកដង្ហើមធំ ប្រះខ្លួនដេកលើពូក ហើយយកទូរសព្ទមកមើល ពេលគឺមិនមែនមើលខោអាវ មើលឡេ ឬកន្លែងដើរលេងដូចមុនទេ តែខ្ញុំមើលព័ត៌មានទាក់ទងនឹងការវិវត្តថ្មីៗរបស់ក្រសួងសុខាភិបាល ឬរដ្ឋាភិបាលអំពីជំងឺកូវីដ-១៩។ ការចាក់វ៉ាក់សាំងគឺជាជម្រើសល្អហើយ តែសំខាន់គឺការអនុវត្ត ៣ កុំ ៣ ការពារ! តែការណ៍នេះសម្រេចទៅមុខបាន អាស្រ័យលើពលរដ្ឋម្នាក់ៗចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវ! ចុះបើដូចបងប្រុសខ្ញុំ ដើរលេងផឹកស៊ី ជួបជុំមិត្តភក្តិ អត់មើលកាលៈទេ-សៈអ៊ីចឹង តើមានគ្រូបាអាចារ្យណាមកពន្យល់គាត់ស្តាប់នោះ បើសូម្បីអាយុជីវិតអ្នកផ្ទះមិនសំខាន់ដល់កែវស្រាគាត់ផងហ្នឹង! ខ្ញុំបាន unfollow ផេកខោអាវ ស្បែកជើង កាបូបដែលខ្ញុំធ្លាប់ខ្ជះខ្ជាយលុយទៅទិញ។ ជំនួសមកវិញ ខ្ញុំបានប្តូរមក follow ផេកដែលលក់បន្លែផ្លែឈើសុវត្ថិភាព ដើម្បីកុម្ម៉ង់ទិញញ៉ាំ ពីព្រោះនៅពេលនេះសុខភាពដែលបានមកពីការទទួលទានអាហារមានជីវជាតិគឺសំខាន់បំផុត! ខ្ញុំភ្លេចប្រាប់ ប្រាក់ខែខ្ញុំត្រូវបានកាត់អស់ ៤០% ដោយសារតែផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើក្រុមហ៊ុនដែលខ្ញុំធ្វើការ។ ខ្ញុំលាក់រឿងនេះនឹងម៉ាក់ប៉ា ព្រោះខ្លាចគាត់ពិបាកចិត្ត។ ខ្ញុំបានយកលុយសន្សំទៅដើរលេងនៅស្រុកក្រៅ មកចាយបណ្តោះអាសន្នសិន ទម្រាំគ្រប់យ៉ាងវិលមករកភាពល្អប្រសើរវិញ។ សំណាងហើយដែលខ្ញុំមិនទាន់សម្រេចចិត្តទិញផ្ទះបង់រំលោះ កុំអីវ័ណ្ឌកនឹងបំណុលមិនខាន។ គិតៗទៅ កូវីដ-១៩ វាឡើងសេរីរហូត ហើយវាគ្មានស្គាល់ថាអ្នកណាជាអ្នកណាទេ ឱ្យតែប្រហែស និងមើលងាយវា ដឹងតែមានហានិភ័យមិនខាន!

គ្រួសារខ្ញុំ និងមនុស្សទាំងអស់នៅលើពិភពលោកត្រូវតែរៀនរស់នៅក្នុងទម្លាប់ថ្មី ឬនិយាយយ៉ាងខ្លីថារៀនរស់ជាមួយនឹងជំងឺកូវីដ-១៩ បើទោះជាយើងមានវ៉ាក់សាំងហើយក៏ដោយ។ សូម្បីតែបងប្រុសរបស់ខ្ញុំដែលត្រូវរៀបការនៅខែក្រោយ ក៏ប្តូរមកត្រឹមជាសែនវិញសិនដែរ ដោយសារតែកូវីដផ្ទុះខ្លាំងពេក។ ចាស់ទុំទាំងសងខាងសម្រេចថាសែន និងចុះសំបុត្រអាពាហ៍ពិពាហ៍សិន ហើយចាំពេលកូវីដស្ងប់ ទើបរៀបការតាមក្រោយ។ បង

ប្រុសខ្ញុំទៅជាអរ ដោយសារគាត់ថាបើការគឺអស់លុយច្រើនជាងសែន តែខាងបងថ្លៃខ្ញុំមិនសប្បាយចិត្តប៉ុន្មានទេ ពីព្រោះការរៀបការគឺជាថ្ងៃដែលសំខាន់បំផុតសម្រាប់ជីវិតរបស់មនុស្សស្រី ហើយសំខាន់ពេលរៀបការគឺបានតែងខ្លួនស្អាតជាងពេលណាៗទាំងអស់នៅក្នុងឆាកជីវិត! តែគាត់ក៏គ្មានជម្រើសដូចគ្នា ធ្វើម៉េចបើទំនៀមទម្លាប់ប្រពៃណីពីដូនពីតាមមក ក៏ឃាត់ភាពប្រែប្រួលក្នុងការរស់នៅ ជីវភាព ទំនៀមទម្លាប់ប្រពៃណី ដែលបង្កឡើងដោយកូវីដមិនបានដែរ! បើមិនសម្របតាមវា មានតែប្រឈមនឹងការឆ្លង! កូវីដវាមិនចេះសម្របខ្លួន វាមិនចេះខ្លាច វាមិនចេះក្រែងចិត្តមនុស្សណាទេ!

ទោះជិតដល់ពេលសែនហើយក៏ដោយ ក៏បងប្រុសខ្ញុំនៅបន្តការដើរលេងផឹកស៊ីដាច់យប់ដដែល! ខ្ញុំនឹកអាណិតអានាគតបងថ្លៃខ្ញុំតើ! តែមិនដឹងធ្វើម៉េចទេ បើគាត់ស្រឡាញ់បងខ្ញុំ គាត់មានតែត្រូវទទួលយកគុណវិបត្តិមួយនេះរបស់បងប្រុសខ្ញុំ! តែបើខ្ញុំវិញណា គឺប៉ងជៀសតែម្តង ប្តី ឬសង្សារចរិតបងប្រុសខ្ញុំ! មនុស្សម្នាក់ដែលមិនគិតសូម្បីអាយុជីវិតគ្រួសារផង តើទៅរំពឹងអីបាន?

ប៉ុន្មានថ្ងៃក្រោយមក បងប្រុសរបស់ខ្ញុំក៏ចាប់ផ្តើមមានអាការផ្តាសាយ និងឈឺកតិចតួចៗ គាត់ប្រញាប់ធ្វើតេស្តរហ័សដោយខ្លួនឯង ហើយក៏ស្រាប់តែគាត់វិជ្ជមានកូវីដ-១៩។ ដើម្បីឱ្យកាន់តែច្បាស់ គាត់ក៏ទៅធ្វើតេស្ត PCR មួយតង់ទៀត! លទ្ធផលបញ្ជាក់ច្បាស់ថាគាត់ពិតជាមានវិជ្ជមានកូវីដ-១៩មែន។ អ្វីដែលខ្ញុំខ្លាចក៏បានមកដល់! គ្រួសាររបស់ខ្ញុំទាំងអស់ត្រូវធ្វើតេស្តកូវីដ-១៩។ ជាសំណាងល្អ តេស្តលើកទី ១ របស់យើងគឺលទ្ធផលអវិជ្ជមាន! យើងអរពាក់កណ្តាល ហើយនៅបារម្ភពាក់កណ្តាល ពីព្រោះយើងត្រូវធ្វើតេស្តលើកទី ២ ម្តងទៀត និងធ្វើចត្តាឡីស័ក ក្នុងរយៈពេល ១៤ ថ្ងៃ ដើម្បីឱ្យប្រាកដថាយើងមិនបានឆ្លងពីបងប្រុស។ ខ្ញុំបារម្ភពីសុខភាពប៉ាម៉ាក់របស់ខ្ញុំខ្លាំងណាស់។ ខ្ញុំខំលួងលោមគាត់ ហើយធ្វើម្ហូបជូនពួកគាត់ ដោយរក្សាអនាម័យបំផុត។ ពួកយើងនៅផ្ទះជុំគ្នា ដូច្នេះយើងពាក់ម៉ាស ពេលត្រូវចុះមកក្រោម ឬធ្វើម្ហូប។ ចំពោះម្ហូបអាហារវិញ គឺសំណាងដែលយើងអាចកុម្ម៉ង់តាមអេប ពេលខ្លះរ៉ឺម៉កម៉ូតូលក់បន្លែម្ហូប ជិះចូលមកលក់ក្នុងបុរីដែលយើងរស់នៅ។ ខ្ញុំគ្រាន់តែស្រែកប្រាប់អ្នកលក់ថាយកអីខ្លះ ហើយគេក៏ដាក់លើកៅអីមុខផ្ទះ ឯខ្ញុំក៏

ដាក់លុយមុខផ្ទះ។ អ្វីដែលចេញនិងចូលសុទ្ធតែត្រូវបាញ់អាល់កុលសម្លាប់មេរោគទាំងអស់។ ថ្ងៃខ្លះមិនមានបន្លែដែលម៉ាក់ប៉ាចង់ពិសា យើងក៏ពឹងអ្នកជិតខាងណាដែលគេទៅផ្សារឱ្យជួញទិញឱ្យ។ អ្នកជិតខាងខ្ញុំល្អណាស់ គេមិនរើសអើងអ្នកផ្ទះខ្ញុំដែលមានសមាជិកកើតកូវីដទេ។ ពោលគឺគេជួយទិញនូវអ្វីដែលយើងត្រូវការ! គិតៗទៅ ពេលលំបាក ហើយបានជួបមនុស្សសប្បុរស យើងមានការកក់ក្ដៅច្រើន ហើយយើងនឹងចងចាំទឹកចិត្តនេះ! យើងជូនពរ និងប្រាថ្នាឱ្យពួកគេជៀសឆ្ងាយពីកូវីដ! តែបើពួកគេនៅតែជួប យើងនឹងជួយពួកគេវិញ! កូវីដវាអាក្រក់ហើយ ដូច្នេះមនុស្សត្រូវមានទឹកចិត្ត និងចេះជួយគ្នាទៅវិញទៅមក! ធ្មេចបើកៗ យើងក៏បានធ្វើតេស្តលើកទី ២ ហើយលទ្ធផលគឺអវិជ្ជមាន! យើងសប្បាយចិត្តខ្លាំងណាស់ ឯបងប្រុសដែលកំពុងព្យាបាលនៅពេទ្យក៏អរដែរ ពេលឮថាពួកយើងមិនអី! ខ្ញុំសង្ឃឹមថាបងប្រុសខ្ញុំចេះគិតពីគ្រួសារជាងមុន ហើយពេលមកផ្ទះវិញ គាត់នឹងឈប់ដើរលេងផឹកស៊ីនាំជំងឺចូលផ្ទះទៀត!

ក្រោយចប់ចត្តាឡីស័ក ខ្ញុំក៏ត្រូវត្រឡប់ទៅធ្វើការតាមកាលវិភាគដែលក្រុមហ៊ុនបានកំណត់! រឿងរ៉ាវរបស់បងប្រុសខ្ញុំ ធ្វើឱ្យខ្ញុំកាន់តែមានការប្រុងប្រយ័ត្នជាងមុនឆ្ងាយណាស់។ ខ្ញុំចាប់ផ្ដើមចេះក្រោកពីព្រឹកធ្វើបាយទឹកសម្រាប់គ្រួសារ ហើយខ្ញុំយកបាយម្ហូបមកធ្វើការ ពីព្រោះលែងហ៊ានហូបអីនៅក្រៅដូចមុនហើយ បើហូបក៏ហូបទាំងភ្នែកនៅកញ្ជ្រឹងក ឬក៏ហូបហើយចេះតែបារម្ភថាខ្លាចឆ្លង។ ហិហិ យី! បើចេះខ្លាចអ៊ីចឹងតាំងពីដើម បែបសល់លុយច្រើនហើយ! តែបានអីនឹងខ្លាច បើកាលហ្នឹងគ្មានកូវីដផងហ្នឹង! ប្រយ័ត្នពេក សូម្បីតែទឹកផឹក ក៏ខ្ញុំត្រូវដាក់ពីផ្ទះមកមួយថ្ងៃ ២ លីត្រដែរ ពីព្រោះធុងចម្រោះទឹក ប្រើគ្នាច្រើនចេះតែខ្លាចទៅ! សូម្បីបន្ទប់ទឹក ប្រដាប់កាច់ទឹក គឺសុទ្ធតែត្រូវខ្ញុំបាញ់អាល់កុលទាំងអស់មុន និងក្រោយពេលប្រើ ដើម្បីបង្ការរឿងឆ្លង និងមិនចង់ឱ្យអ្នកប្រើក្រោយដែលភ្លេចបាញ់អាល់កុលមានហានិភ័យ។ "គ្រប់គ្នានឹងគ្មានសុវត្ថិភាពនោះទេ ប្រសិនបើគ្មានអ្នកណាម្នាក់មានសុវត្ថិភាពៗ" នេះគឺជាឃ្លាដែលខ្ញុំយកមកបង្ក្រាបភាពអាត្មានិយម ក្នុងកាលៈទេសៈនៃការរីករាលដាលជំងឺកូវីដ-១៩។ បន្ទប់ប្រជុំ ដែលធ្លាប់តែមានមនុស្សក្បែរ ១០ នាក់ រាល់ការប្រជុំម្ដងៗ ត្រូវកាត់មកសល់ត្រឹម ៤ នាក់ ហើយសល់ប៉ុន្មានគឺប្រជុំតាម Zoom។

វារាងពិបាក ព្រោះពេលខ្លះអ៊ីនធឺណិតយឺត ប្រជុំៗដាច់បាត់ ហើយស្តាប់មិនច្បាស់ក៏មាន តែយើងគ្រប់គ្នាគ្មានជម្រើស។ ការធ្វើការងារក្នុងសម័យកូវីដ មិនមែនបានន័យថាធ្វើការងារបានល្អ ចប់សព្វគ្រប់ទៅតាមកាលកំណត់ ហៅថាជាបុគ្គលិកល្អ និងមានទំនួលខុសត្រូវនោះទេ តែចាំបាច់ត្រូវពាក់ម៉ាស រក្សាគម្លាតថែមទៀតផង។ គេក៏មានគ្រួសារ យើងក៏មានគ្រួសារ! យើងស្រឡាញ់គ្រួសារយើង គេក៏ស្រឡាញ់គ្រួសារគេ! យើងក៏ត្រូវប្រុងប្រយ័ត្ន! គេក៏ត្រូវប្រុងប្រយ័ត្ន! រៀងរាល់ពេលមកដល់ផ្ទះ ខ្ញុំត្រូវបាញ់អាល់កុលស្បែកជើង បាញ់ខោអាវ ហើយក៏ប្រញាប់ចូលបន្ទប់ រួចដោះខោអាវចេញយកទៅត្រាំទឹកដាក់សាប៊ូ រួចរង់ចាំពី ១៥ ទៅ ៣០ នាទីទើបមុជទឹក។ ដោយសារផ្ទះខ្ញុំមានបន្ទប់ទឹកតែពីរ គឺមួយនៅក្នុងបន្ទប់ម៉ាក់ប៉ា និងមួយទៀតនៅខាងក្រោម ដែលខ្ញុំប្រើរួមនឹងបងប្រុស ដូច្នេះខ្ញុំតែងបាញ់ដៃនឹងអាល់កុល មុនពេលខ្ញុំចាប់កាន់ទ្វារ និងក្បាលរ៉ូប៊ីនេ។ បង្គន់វិញ ខ្ញុំត្រូវតែបាញ់អាល់កុន មុន និងក្រោយពេលប្រើប្រាស់ដូចគ្នា។ ខ្ញុំមានសម្ភារៈបន្ទប់ទឹកផ្សេងពីបងប្រុសខ្ញុំតាំងពីសាប៊ូដុសខ្លួន សាប៊ូកក់សក់ សាប៊ូលាងដៃ ហ្វូមលាងមុខ ផ្តិលទឹកជាដើម ពីព្រោះវាជួយកាត់បន្ថយហានិភ័យនៃការឆ្លង។ ខ្ញុំលែងហ៊ានញ៉ាំបាយជាមួយម៉ាក់ប៉ាទៀតហើយ ដោយសារខ្ញុំខ្លួនឯងចេះតែខ្លាចថាខ្ញុំចេញទៅក្រៅធ្វើការហើយ ជួបមនុស្សនៅខាងក្រៅ ទោះប្រយ័ត្នយ៉ាងណា ក៏ខ្ញុំនៅតែខ្លាចថាខ្លួនអាចឆ្លងជំងឺនេះជាយថាហេតុ ដូច្នេះដើម្បីសុខភាពម៉ាក់ប៉ា ខ្ញុំក៏ប្រើប្រាស់ចានស្លាបព្រាផ្ទាល់ខ្លួន មានសាប៊ូលាងចាន និងប៉ុងលាងចានដោយឡែក ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លង។ អូ! សូម្បីតែកែវទឹកវិញ ក៏អ្នកផ្ទះខ្ញុំរកប្រើផ្សេងគ្នាដែរ! ហ៊ឹម... ការជួបជុំដែលពីមុនដែលយើងមានឱកាស តែមិនចេះស្រវ៉ា ហើយស្រាប់តែពេលលែងមានឱកាស ខណៈចិត្តចង់បាន ក៏ស្រាប់កាលៈទេសៈមិនអំណោយផល!

ខ្ញុំចេះតែបន្តទម្លាប់បែបគន្លងថ្មីៗនេះ រហូតដល់ខ្ញុំមានអារម្មណ៍ស៊ាំនឹងវា! តែមានអារម្មណ៍មួយដែលខ្ញុំពិបាកនឹងទ្រាំ គឺភាពអផ្សុក និងធុញទ្រាន់! ខ្ញុំចង់ដើរលេង! ខ្ញុំចង់ទៅក្រៅស្រូបយកបរិយាកាសល្អៗ និងខ្យល់ត្រជាក់ៗ! ទ្រាំមិនបាន ខ្ញុំក៏ឆៃតទៅមិត្តរបស់ខ្ញុំដើម្បីយើងទៅដើរលេងបែបលក្ខណៈពិកនិក ដោយយើងយកអាហារពីផ្ទះទៅ ហើយ

យើងប្រយ័ត្នគ្រប់គ្នាទៅ នោះយើងនឹងអាចទៅដើរលេងបានហើយ។ មិត្តភក្តិខ្ញុំដែលស្រែ្ត សដល់កម្រិត ៩ ដូចគ្នាហ្នឹងក៏សម្រេចថាយើងនឹងទៅដើរលេងជាមួយគ្នា ព្រោះយើងទុកចិត្តគ្នា ហើយណាមួយយើងសុទ្ធតែចាក់វ៉ាក់សាំងរួចគ្រប់គ្នាទៀត ម្យ៉ាងកន្លែងយើងទៅហ្នឹងគឺគិរីរម្យ ដែលមានខ្យល់អាកាសបរិសុទ្ធ ហើយមិនខ្លាចអ្នកណាមកជិតពួកយើងបាននោះទេ។ យើងដើរលេងដោយសប្បាយរីករាយ បើទោះជាយើងដោះម៉ាស់តែពេលញ៉ាំបាយ និងពេលថតរូប ហើយត្រូវបាញ់អាល់កុលជាញឹកញាប់ ជាពិសេសបាញ់បាតស្បែកជើងនិងខោអាវនៅពេលចូលឡានក៏ដោយ ក៏ពួកយើងមិនសាញ។ នេះគេហៅថាដើរលេងប្រកបដោយទំនួលខុសត្រូវ!

មកពីដើរលេងមិនបានប៉ុន្មានថ្ងៃ កន្លែងដែលខ្ញុំទៅដើរលេងហ្នឹង ខាងរដ្ឋប្រកាសថាមានអ្នកផ្ទុក កូវីដទៅលេងដែរ ដូច្នេះបើមានបងប្អូនណាបានទៅ សូមតាមដានអាការរបស់ខ្លួន និងដាក់ខ្លួនដាច់ដោយឡែកឱ្យបាន ១៤ ថ្ងៃ។ គ្រាន់តែឃើញអ៊ីចឹងភ្លាម ខ្ញុំក៏គិតក្នុងចិត្ត "សប្បាយ ១ ថ្ងៃ ឃុំខ្លួន ១៤ ថ្ងៃទៀតហើយអញ!"។ បើទោះជាខ្ញុំដឹងថាខ្ញុំមិនសូវមានហានិភ័យខ្ពស់ក៏ដោយ តែរឿងរ៉ាវរបស់បងប្រុសខ្ញុំ នៅជិតជាប់នឹងចិត្តខ្ញុំ ហើយខ្ញុំក៏មិនចង់នាំទុក្ខដល់អ្នកផ្ទះ និងអ្នកនៅកន្លែងធ្វើការ ដូច្នេះខ្ញុំក៏សម្រេចនៅក្នុងបន្ទប់រយៈពេល ១៤ ថ្ងៃ ហើយបាយទឹកគឺមានតែពឹងលើម៉ាក់ ១៤ ថ្ងៃនេះសិនចុះ! ខ្ញុំចេះតែគិត បើខ្ញុំទៅលេងស្រុកគេ ពេលកូវីដស្រាកស្រាន្ត តើវានឹងពិបាកដូចពេលនេះឬអត់? ទាំងការស្នាក់នៅ ការហូបចុកនៅផ្ទះ អនាម័យមួយចប់ហើយ នៅតែមានចិត្តភ័យខ្លះៗ ចុះទម្រាំទៅដើរលេងស្រុកគេទៀត? គេនឹងខ្វល់ពីសុវត្ថិភាពអ្នកទេសចរ ដូចម្ដាយឪពុកខ្ញុំធ្វើចំពោះខ្ញុំឬក៏អត់ហ្ន៎!

យប់នេះជាយប់ចុងក្រោយនៃការធ្វើចត្តាឡីស័ករបស់ខ្ញុំហើយ ខ្ញុំមើលរូបថតចាស់ក្រោយពីអានសៀវភៅរួច។ ខ្ញុំនឹកដល់ពេលវេលាពីមុន ដែលខ្ញុំគិតថាមនុស្សលើផែនដីរួមទាំងខ្ញុំគឺមានសំណាងខ្លាំងណាស់ ហើយមានឱកាសច្រើនទៀត តែមនុស្សបែរជាមើលរំលង។ សូម្បីតែការជួបជុំគ្រួសារ ដែលជាពេលវេលាដ៏មានតម្លៃបំផុត ក៏ខ្ញុំមើលរំលងចោលអស់រាប់ឆ្នាំ! ដល់ពេលមានចិត្តចង់ជួបជុំ ក៏ស្រាប់តែមិនអាចស្និទ្ធស្នាលដូចមុន!

នៅអំឡុងពេលកូវីដ ខ្ញុំចាប់ផ្តើមឃើញពីតម្លៃនៃសុខភាព។ ខ្ញុំប្រាថ្នាមិនត្រឹមតែឃើញគ្រួសារទាំងមូលមានសុខភាពល្អទេ តែចង់ឃើញមនុស្សទូទាំងពិភពលោកមានសុខភាពល្អ រស់នៅប្រកបដោយក្តីស្រឡាញ់ ចេះជួយគ្នា។

ហឹម...ជីវិតរីករាយកាលពីម្សិលមិញ ទោះជាល្អយ៉ាងណាក៏នៅតែមិនអាចត្រឡប់ទៅវិញបាន! ថ្ងៃនេះរស់នៅជាមួយកូវីដ ចុះថ្ងៃស្អែក មានស្អីមកទៀត?

ជីវិតនៅថ្ងៃអនាគត ទោះជាចង់ឱ្យល្អយ៉ាងណា ក៏នៅតែជារឿងដែលយើងមិនអាចកំណត់បាន ហើយស្មានមិនត្រូវ!

តែជីវិតនៅថ្ងៃនេះ គឺជាឱកាស ដែលយើងត្រូវតែថែរក្សា ទទួលយកការពិត ហើយរៀនរស់នៅជាមួយវាដោយភាពក្លាហាន និងជម្នះរាល់ឧបសគ្គដែលមាននៅក្នុងថ្ងៃនេះ!

ថ្ងៃនេះមានវត្តមាននៃជំងឺកូវីដ-១៩ ហើយយើងមិនដឹងថាថ្ងៃស្អែកនឹងមានជំងឺអ្វីទៀតដែលសាហាវដូចវា ឬសាហាវជាងវានោះទេ តែអ្វីដែលសំខាន់នៅពេលនេះគឺ...

សំឡេងចាក់សោរទ្វារចូលមក ហើយខ្ញុំក៏ដឹងហើយថាជាអ្នកណា គឺបងចិត្រាដែលទើបមកពីដើរលេង...

ខ្ញុំដាច់អស់ការគិត ហើយបានត្រឹមតែដកដង្ហើមធំ គិតក្នុងចិត្តៈ

- កូវីដគួរឱ្យខ្លាចមែន តែអ្វីដែលរឹតតែគួរឱ្យខ្លាច គឺទម្លាប់អាក្រក់របស់មនុស្សដែលនៅតែបន្ត ដដែលៗ រហូតដល់ផ្តល់ផលវិបត្តិផ្សេងៗគ្នាដល់មនុស្សដូចគ្នានៅពេលខាងមុខ! ម្សិលមិញ ខុសពីថ្ងៃនេះ ចុះថ្ងៃស្អែកវិញ?